លេខ ២ ចេញផ្សាយថ្ងៃទី១ ខែសីហា ឆ្នាំ២០២១

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែកក្កដា ឆ្នាំ២០២១

**និយ័តករបរធនបាលកិច្ច**
**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ**
**បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

## កិច្ចប្រជុំផ្លាស់ប្តូរ និងដកស្រង់ បទពិសោធន៍ពាក់ព័ន្ធនឹងបរធនបាលកិច្ច

នាព្រឹកថ្ងៃព្រហស្បតិ៍ ៧រោច ខែបឋមសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្តម **នេង ពិសិដ្ឋ** និងឯកឧត្តម **ឈឹ សាគល** អគ្គនាយករងនៃ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំមន្ត្រីជំនាញចូលរួមកិច្ចប្រជុំផ្លាស់ប្តូរ និងដកស្រង់បទពិសោធន៍ពាក់ព័ន្ធនឹងបរធនបាលកិច្ច ជាមួយលោកបណ្ឌិត James Chang ស្ថាបនិកក្រុមហ៊ុន The First China Investment និង Trust Investment Committee of NKUST Affair Funds ព្រមទាំងក្រុមការងារ។ កម្មវិធីខាងលើ បានប្រព្រឹត្តទៅដោយរលូន និងប្រកបដោយផ្លែផ្កា។




រូបភាពក្នុងកិច្ចប្រជុំផ្លាស់ប្តូរ និងដកស្រង់បទពិសោធន៍ពាក់ព័ន្ធនឹងបរធនបាលកិច្ច តាមប្រព័ន្ធអនឡាញ ក្រោមការដឹកនាំរបស់ឯកឧត្តម **នេង ពិសិដ្ឋ** និងឯកឧត្តម **ឈឹ សាគល**។

## មាតិកា


- កិច្ចប្រជុំផ្លាស់ប្តូរ និងដកស្រង់បទពិសោធន៍ពាក់ព័ន្ធនឹងបរធនបាលកិច្ច ទំព័រ ១
- កិច្ចប្រជុំតាមប្រព័ន្ធអនឡាញជាមួយតំណាងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ទំព័រ ២
- កិច្ចប្រជុំតាមប្រព័ន្ធអនឡាញ ដើម្បីពិភាក្សាបញ្ចប់កម្រិតផ្ទៃក្នុងនូវសេចក្តីព្រាងប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទនៃ ន.ប.ធ. ទំព័រ ២
- កិច្ចប្រជុំថ្នាក់ដឹកនាំដើម្បីពិភាក្សាលើសេចក្តីព្រាងរបាយការណ៍លទ្ធផលនៃការអនុវត្តថវិកាឆមាសទី១ ទំព័រ ២
- សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈលើសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ទំព័រ ៣
- កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពី "វិធានគោលក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច" ទំព័រ ៤




អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំតាមប្រព័ន្ធអនឡាញជាមួយតំណាងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)

នាព្រឹកថ្ងៃព្រហស្បតិ៍ ៧រោច ខែបឋមសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច បានចូលរួមប្រជុំតាមប្រព័ន្ធអនឡាញជាមួយតំណាងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **វង់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដោយមានការចូលរួមពីឯកឧត្តមអគ្គលេខាធិការ ឯកឧត្តមប្រតិភូ និងឯកឧត្តមអគ្គនាយកនៃនិយ័តករចំណុះឱ្យ **អ.ស.ហ.** ដើម្បីពិភាក្សាអំពីកិច្ចគាំទ្របច្ចេកទេសក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។



រូបភាពក្នុងកិច្ចប្រជុំតាមប្រព័ន្ធអនឡាញជាមួយតំណាងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **វង់ សីលវ៉ា**។

## កិច្ចប្រជុំតាមប្រព័ន្ធអនឡាញ ដើម្បីពិភាក្សាបញ្ចប់កម្រិតផ្ទៃក្នុងនូវសេចក្តីព្រាងប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទនៃ ន.ប.ធ.

នារសៀលថ្ងៃសុក្រ ៨រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយឯកឧត្តមអគ្គនាយករង **នង ពិសិដ្ឋ** និងឯកឧត្តមអគ្គនាយករង **ណី សាគល** បានដឹកនាំកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ ដើម្បីពិភាក្សាបញ្ចប់កម្រិតផ្ទៃក្នុងនូវសេចក្តីព្រាងប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទនៃ **ន.ប.ធ.**។



រូបភាពក្នុងកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ ដើម្បីពិភាក្សាបញ្ចប់កម្រិតផ្ទៃក្នុងនូវសេចក្តីព្រាងប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទនៃ **ន.ប.ធ.**។

## កិច្ចប្រជុំថ្នាក់ដឹកនាំដើម្បីពិភាក្សាលើសេចក្តីព្រាងរបាយការណ៍លទ្ធផលនៃការអនុវត្តថវិកាឆមាសទី១

នាព្រឹកថ្ងៃចន្ទ ១១រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានចូលរួមកិច្ចប្រជុំថ្នាក់ដឹកនាំតាមប្រព័ន្ធវីដេអូ ដើម្បីពិភាក្សាលើសេចក្តីព្រាងរបាយការណ៍លទ្ធផលនៃការអនុវត្តថវិកាឆមាសទី១, ការប៉ាន់ស្មានលទ្ធផលនៃការអនុវត្តថវិកាឆ្នាំ២០២១ និងគោលការណ៍សំខាន់ៗសម្រាប់អនុវត្តឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការចូលរួមពីឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំ និងមន្ត្រីតំណាងអគ្គនាយកដ្ឋាន និងនិយ័តករពាក់ព័ន្ធ។




រូបភាពក្នុងកិច្ចប្រជុំកិច្ចថ្នាក់ដឹកនាំដើម្បីពិភាក្សាលើសេចក្ដីព្រាងរបាយការណ៍លទ្ធផលនៃការអនុវត្តថវិកាឆមាសទី១ តាមប្រព័ន្ធវីដេអូ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្ដមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**។

## សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈលើសេចក្ដីព្រាងច្បាប់ស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ

នាព្រឹកថ្ងៃព្រហស្បតិ៍ ៥រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្ដអគ្គនាយករង **នង ពិសិដ្ឋ** តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្ដម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច **(ន.ប.ធ.)** បានដឹកនាំមន្ដ្រីជំនាញចូលរួមសិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈលើសេចក្ដីព្រាងច្បាប់ស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដែលរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។




រូបភាពក្នុងសិក្ខាសាលាក្រោមការដឹកនាំរបស់ឯកឧត្ដម **នង ពិសិដ្ឋ** តាមប្រព័ន្ធអនឡាញ ។

## កិច្ចប្រជុំពិភាក្សាលើសេចក្ដីព្រាងប្រកាសស្ដីពី "វិធានគោលក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច"

នាព្រឹកថ្ងៃសុក្រ ៦រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយឯកឧត្តមអគ្គនាយករង និងមន្ត្រីជំនាញ បានដឹកនាំកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពី "វិធានគោលក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច" ក្នុងគោលបំណងទទួលបានធាតុចូលបន្ថែមពីភាគីពាក់ព័ន្ធដែលមានការចូលរួមពីតំណាងអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ**) និយ័តករមូលបត្រកម្ពុជា និយ័តករធានារ៉ាប់រងកម្ពុជា និយ័តករគណនេយ្យនិងសវនកម្ម និយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ និយ័តករសន្តិសុខសង្គម អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាផងដែរ។

សេចក្តីព្រាងប្រកាសនេះ មានគោលបំណងគ្រប់គ្រងរាល់សកម្មភាព និងប្រតិបត្តិការបរធនបាលកិច្ចក្នុងការគ្រប់គ្រងចាត់ចែង និងថែរក្សាទ្រព្យសម្បត្តិជំនួសឱ្យអ្នកដទៃ ដើម្បីជាប្រយោជន៍ដល់អត្ថគាហកៈ ឬបុគ្គលណាមួយ ដោយកំណត់អំពីលក្ខខណ្ឌ និងនីតិវិធីក្នុងការផ្តល់ការអនុញ្ញាតពី **ន.ប.ធ.** ឱ្យបង្កើតដំណើរការ និងចុះបញ្ជីបរធនបាលកិច្ច ព្រមទាំងការផ្តល់អាជ្ញាបណ្ណ និង/ឬការអនុញ្ញាតដល់ប្រតិបត្តិករបរធនបាល តាមរយៈការកំណត់សិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវក្រោមលក្ខខណ្ឌអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតនោះ។




រូបភាពក្នុងពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពី "វិធានគោលក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច" តាមប្រព័ន្ធអនឡាញ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ ដារ៉ា** ។